# កិច្ចសំភាសន៍មីង ដួង ណារី

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ដួង ណារី

កៈ ចាស ជាដំបូងសុំជំរាបសួរអ្នកមីង?

ខៈ ចាស ជំរាបសួរក្មួយ។

កៈ ចាស ថ្ងៃនេះផងដែរក្មួយមានឧកាសដើម្បីសំភាសន៍អ្នកមីងផ្ទាល់ មិនថាខ្ញុំគួរតែហៅមីងឬក៏ហៅអ៊ីដែរចាស?

ខៈ ហៅមីងចុះព្រោះយើងជាខ្មែរណាក្មួយ។

កៈ ចាស ចឹងខ្ញុំសុំថាអ្នកមីង ចាសអ្នកមីងថ្ងៃនេះក្មួយមកពីសាលា BYU នៅកោះហាវ៉ៃ ចាស។

ខៈ នៅខាងណាក្មួយដូចមិនដែលលឺក្មួយ?

កៈ អ៊ី នៅសហរដ្ឋអាមេរិចក្នុងកោះហាវ៉ៃចាស។

ខៈ អូ កោះហាវ៉ៃហ្អេ?

កៈ ចាសអ្នកមីង កោះហាវ៉ៃនៅសហរដ្ឋអាមេរិក។

ខៈ អូ ធ្លាប់លឺ។

កៈ ចាស ហើយសាលា BYU មានទីស្នាក់ការនៅនឹង ហើយពេលនេះដែរសាលាមានពង្សប្រវត្តិមួយដែលទាក់ទងនិងប្រវត្តិរបស់ប្រជាជនកម្ពុជា ពួកគាត់ចង់បានប្រវត្តិរបស់ប្រជាជនកម្ពុជាដែលមានអាយុចាប់ពី ៣៥ ឆ្នាំឡើងទីយកមកចងក្រងទុកជាឯកសារសំរាប់កូនចៅជំនាន់ក្រោយបានដឹងជាពិសេសទាក់ទងនឹងបទពិសោធន៍ជីវិតនៅក្នុងរបបពលពតដែលគាត់បានឆ្លងកាត់តាំងពីដើមរហូតមកដល់បច្ចុប្បន្នថា តើគាត់មានទុក្ខលំបាកអីខ្លះ? នឹងមានការចងចាំអ្វីខ្លះ? ចឹងហើយខាងគំរោងចង់រក្សាទុកនូវឯកសារដែលជាប្រវត្តិរបស់ប្រជាជនកម្ពុជានឹង ចាស ហើយបន្ទាប់ពីសំភាសន៍ចប់ក្មួយនឹងផ្ញើរសំលេងរបស់អ្នកមីងអោយខាងគំរោងជាអ្នករក្សាទុក។ ចាសចឹង តើអ្នកមីងអនុញ្ញាតអោយក្មួយបានសំភាសន៍ដែរឬទេ?

ខៈ ចាសក្មួយ អត់អីទេសំភាសន៍បាន។

ក៖ ចាស អរគុណច្រើនអ្នកមីង។ ចឹងក្មួយសុំស្គាល់ឈ្មោះរបស់មីង តើអ្នកមីងឈ្មោះអីដែរ?

ខ៖ មីងឈ្មោះ រី។

ក៖ ចាស អ្នកមីងរី ចាសហើយចុះឈ្មោះរបស់អ្នកមីងត្រូវនឹងអត្តញ្ញាណប័ត្រដែរឬទេ?

ខ៖ ចាស ត្រូវក្មួយ។

ក៖ ចាស ចឹងក្នុងអត្តសញ្ញាណប័ត្ររបស់មីងឈ្មោះរបស់មីងពេញទាំងនាមត្រកូល ឈ្មោះអីដែរ?

ខ៖ ឈ្មោះពេញរបស់មីង ដួង ណារី។

ក៖ ចាស អ្នកមីង ដួង ណារី។ ចាសចឹងសព្វថ្ងៃអ្នកមីងមានអាយុប៉ុន្មានឆ្នាំងហើយ?

ខ៖ មីងអាយុ៥៦ហើយក្មួយ។

ក៖ ចាស ចឹងអ្នកមីងចាំថ្ងៃខែឆ្នាំកំណើតរបស់អ្នកមីងដែរទេ?

ខ៖ ចាស ចាំតើក្មួយ។

ក៖ ចាស ចឹងអ្នកមីងកើតថ្ងៃណាខែឆ្នាំណាដែរ?

ខ៖ មីងកើតថ្ងៃទី ៣១ ខែ១២ ១៩៦២ ចាស។

ក៖ ចាស ថ្ងៃទី ៣១ ខែ១២ ឆ្នាំ១៩៦២
ចាសហើយចុះសព្វថ្ងៃនេះអ្នកមីងមានទីលំនៅនៅកន្លែងណាដែរអ្នកមីង?

ខ៖ មីងនៅនឹងម៉ងក្មួយ

ក៖ ចាស នៅភូមិ ឃុំ ណាដែរ?

ខ៖ នៅភូមិស្ទឹងជ្រៅ ឃុំតាមៀន ទីក្រុងតាខ្មៅ។

ក៖ ចាស ហើយអ្នកមីងមានដែលធ្លាប់ប្តូរទីលំនៅដែរឬទេ?

ខ៖ ពីមុននោះមីងនៅបឹងទំពន់ នៅភូមិសន្សំកុសល សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ។

ក៖ ចាស រួចហើយបានអ្នកមីងផ្លាសមករស់នៅទីនេះវិញ?

ខ៖ ចាស!!

កៈ ចឹងអ្នកមីងផ្លាស់ទីលំនៅតែម្តងនឹងទេ?

ខៈ ចាស ផ្លាស់តែម្តងនឹងទេក្មួយ!

កៈ ចាស ចុះចំពោះក្រុមគ្រួសាររបស់អ្នកមីងរស់នៅជុំគ្នា ឬក៏មានបែកទៅនៅកន្លែងផ្សេងទេ?

ខៈ ចាស នៅជុំគ្នា!

កៈ ចាស ចឹងអ្នកមីងមានកូនប៉ុន្មានអ្នកដែរ?

ខៈ មានកូនបីអ្នក ប៉ុន្តែមានម្នាក់គេទៅរស់នៅស្រុកក្រៅបាត់ហើយ។

កៈ ចាស ចុះគាត់ទៅរស់នៅក្នុងប្រទេសណាដែរអ្នកមីង?

ខៈ ទៅនៅសហរដ្ឋអាមេរិចក្មួយ!

កៈ ចាស ចុះគាត់រស់នៅក្នុងរដ្ឋណាដែរ?

ខៈ នៅរដ្ឋណាមីងមិនចាំទេក្មួយ ភ្លេចបាត់ហើយ។

កៈ ចាស ចុះគាត់ទៅរស់នៅបានប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ នៅបីឆ្នាំហើយក្មួយ!

កៈ ចាស គាត់ទៅនឹងតាមរយៈបងប្អូន តាមមិត្តភក្តិ ឬ ក៏ទៅតាមរយៈណាដែរអ្នកមីង?

ខៈ អឺម និយាយទៅគេយកប្រពន្ធនៅនឹង។

កៈ ប្រពន្ធគាត់ជាជនជាតិខ្មែរ ឬក៏ជាជនជាតិគេដែរអ្នកមីង?

ខៈ ជាជនជាតិខ្មែរក្មួយ!

កៈ អូ គាត់ជាជនជាតិខ្មែរតែគាត់ទៅរស់នៅសហរដ្ឋអាមេរិច?

ខៈ ចាស!

កៈ ចាស ហើយចុះគាត់មានកូនហើយឬនៅមីង?

ខៈ ខែក្រោយនេះបានប្រពន្ធគេនឹងសំរាលកូន។

កៈ អូ ចាសចឹងជួយអបអរទេរផងណា! អ្នកមីងកូនរបស់គាត់នឹងស្រីឬក៏ប្រុស?

ខ៖ ចាស ប្រុសក្មួយ។

ក៖ ហើយចុះគាត់មានគំរោងមកលេងជាមួយអ្នកមីងដែរទេ?

ខ៖ អឺ ថ្មីៗនេះនៅមិនទាន់មានទេក្មួយព្រោះគេជាប់រវល់ធ្វើការក្មួយ។

ក៖ ចាស ពួកគាត់ធ្វើការអីដែរអ្នកមីង?

ខ៖ អឹម ប្រពន្ធរបស់វានឹងធ្វើខាងមេកានិច។

ក៖ ចាស ចឹងគាត់ពូកែមែនទែនបានទៅដល់នឹងហើយៗបានធ្វើការខាងមេកានិចទៀត។

ខ៖ ចាស!

ក៖ គាត់រៀនចប់មេកានិចហ៎ អ្នកមីង?

ខ៖ អត់ទេ នៅនេះវារៀនខាងអាយធី និយាយទៅគេស្គាល់គ្នាតាម Facebook ហើយស្រីនឹងគេមានលុយគេមកការយកទៅ។

ក៖ ចាសអ្នកមីង ចុះកាលនឹងអ្នកមីងដឹងថាពួកគាត់ស្រលាញ់គ្នាទេកាលនឹង?

ខ៖ អត់ទេក្មួយ មីងអត់សោះម៉ង ទាល់តែជិតការគេសុំភ្ជាប់ពាក្យនឹងបានដឹង។

ក៖ ចាសចឹង អ្នកមីងត្រេកអរដែរទេ?

ខ៖ ចាសក្មួយ ត្រេកអរ ព្រោះកាលនឹងយើងកំពុងពេញខ្វះខាតក្មួយ។

ក៖ ចាស!

ខ៖ ចាសកាលនឹងមីងជួលផ្ទះគេនៅចាក់អង្រែ ហើយដល់ពេលចឹងទៅគេក៏មករៀបការជាមួយកូនយើងចឹងទៅយើងនឹងត្រេកអរដែលគេមានជួយទំនុកបំរុងកូនយើងអោយបានទៅរស់នៅស្រុកគេនឹង។

ក៖ ចាសអ្នកមីង!

ខ៖ ហើយគេជិតបានកូនមួយហើយ ប្រហែលជាខែក្រោយនឹងប្រពន្ធវានឹងសំរាលកូនហើយ។

ក៖ ចាស ហើយចុះអ្នកមីងមានគំរោងទៅលេងជាមួយពួកគាត់ទេ?

ខ៖ អឺម ដូចជាមិនចង់ទៅទេក្មួយ មិនមែនថាមិនចង់ទៅលេងកូនទេ ចិត្តនោះចិត្តនឹងរលឹកកូនចង់តែទៅលេងកូនទេតែទៅមិនកើតមិនដឹងធ្វើម៉េច។

ក៖ ចាស នៅឆ្ងាយគ្នាពេក!

ខ៖ ចាស នៅឆ្ងាយពេកហើយណាមួយខ្លាចនឹងជិះយន្តហោះជើងវាអត់ដល់ដី(សើច)។

ក៖ (សើច) ចាសអ្នកមីងអត់ហ៊ានជិះយន្តហោះ តែចុះបើមានលុយអ្នកមីងហ៊ានទៅទេ?

ខ៖ ចាស បើមានលុយអាចនឹងពិចារណាដែរណា។

ក៖ ចាស អ្នកមីងទាំងអស់មានកូនបីអ្នក ហើយចុះអ្នកមីងកូនអ្នកមីងមានឈ្មោះអីខ្លះដែរ?

ខ៖ កូនដែលនៅសហរដ្ឋនឹងឈ្មោះ ចាប ប្រាក់យ៉ា កូនទីពីរឈ្មោះ ចាប ផានិត កូនទីបីឈ្មោះ ចាប មិនាស្រី។

ក៖ ចាស!

ខ៖ កូនស្រីមានតែមួយនឹង។

ក៖ ចាស ស្រីពៅគេ!

ខ៖ ចាស ពៅគេហើយនឹង!

ក៖ ចាស អ្នកមីងសព្វថ្ងៃចុះស្វាមីអ្នកមីងនៅឯណាដែរ?

ខ៖ និយាយទៅគាត់ហើយនឹងខ្ញុំដូចតែបែកគ្នាដែរនឹង ព្រោះនៅបែកគ្នាយូរហើយ។

ក៖ អឺ អ្នកមីងលែងលះគ្នាមែនទេមីង?

ខ៖ អត់បានលែងលះគ្នាទេ តែគាត់នៅធ្វើការនៅស្រុកឆ្ងាយ។

ក៖ ចាស ចុះគាត់ទៅធ្វើការអីដែរអ្នកមីង?

ខ៖ ហើយក្មួយ មីងមិនសូវជាដឹងទេខាងក្រសួងនឹង។

គ៖ ខាងរដ្ឋបាល!

ក៖ ចាស គាត់ធ្វើខាងផ្នែករដ្ឋបាល ចឹងអ្នកមីងតើរយះពេលប៉ុន្មានថ្ងៃគាត់មកលេងនឹងអ្នកមីងម្តង?

ខ៖ ពីរបីថ្ងៃ ជួនកាលនឹងកន្លះខែទៅ ពេលណាគេនឹកឃើញមកក៏មកម៉ោ។

ក៖ ហើយចុះពេលដែលគាត់មកម្តងៗនឹងមានអីផ្ញើរអ្នកមីងដែរទេ?

ខ៖ គ្មានអីទេក្មួយ មានតែពងទា ទឹកត្រី ប៊ីចេងអីចឹងទៅ។

ក៖ ចាស នឹកឃើញប្រពន្ធមុនគេ!

ខ៖ ចាស នឹកឃើញប្រពន្ធមុនគេ!

ក៖ ចាស ចឹងគាត់ចុះទៅតាមខេត្តច្រើនដែរទេមីង គាត់ម្តងនឹងប៉ុន្មានខេត្តដែរមីង?

ខ៖ មីងមិនថាគាត់ទៅម្តងៗនឹងប៉ុន្មានខេត្តទេក្មួយ មីងមិនសូវជាចាប់អារម្មណ៏ទេ។

ក៖ ចាស ម៉េចចឹងមីង?
ហើយចុះមីងនឹងលោកពេលដែលរៀបការមីងស្រលាញ់គ្នាឬក៏ឪពុកម្តាយទុកដាក់អោយ?

ខ៖ អឺ ស្រលាញ់គ្នាក្មួយ តែគ្រាន់តែថាបើគាត់ធ្វើការគាត់ដឹងតែធ្វើការនឹងទៅ
តែគាត់ដើរធ្វើការមិនសូវជាបាននៅផ្ទះប៉ុន្មានទេ។

ក៖ ចាស ចឹងកាលជំនាន់អ្នកមីងរៀបការ មីងការនៅជំនាន់ពលពត
ឬក៏បែកពីរពលពតហើយ?

ខ៖ បែកពីពលពតហើយក្មួយ។

ក៖ ចាស បែកពីជំនាន់ពលពតហើយ

ខ៖ មីងការអាយុ ៣៥ ឆ្នាំហើយនឹង។

ក៖ ចាស ហើយម៉េចក៏យូរម្លេះមីង?

ខ៖ ហ៊ើយក្មួយ ចុះបើគ្មានអ្នកគេចូលដណ្តឹងនឹងណា។

ក៖ ចាស និយាយទៅមិនទាន់ដល់គូន៍មីង?

ខ៖ នឹងហើយក្មួយ!

ក៖ ហើយពេលដែលឃើញពូ?

ខ៖ ពេលដែលឃើញពូនឹងក៏ចាប់ផ្តើមមានស្នេហាហើយក៏រៀបការនឹងទៅ។

កៈ ដូចថាជាព្រហ្មលិខិត ឬក៏និស្ស័យអោយអ្នកមីងនឹងលោកពូនឹងបានជួបគ្នា។

ខៈ ចាស និស្ស័យក្មួយនិស្ស័យ ខ្ញុំនិងគាត់ទាល់តែដល់ថ្ងៃរៀបការទើបឃើញមុខគ្នា។

កៈ អឺម ឃើញគ្នាក្នុងថ្ងៃការ ហើយចុះកាលនោះលោកពូធ្វើការនៅឯណាដែរ?

ខៈ កាលនឹងគាត់ធ្វើការជាមេប៉ុស្តិ៍នៅទឹកល្អក់។

កៈ ចាស!

ខៈ ហើយមីងនឹងធ្វើការនៅកាំបូឌីយ៉ាណា ហើយទៅគាត់ក៏មិនស្គាល់មីងដែរ តែចេះតែលួចមើលគ្នាតាមកន្ទុយភ្នែក ឃើញតែតាមរយៈរូបថតតែមនុស្សមិនដែលឃើញទេ ហើយតែទៅផ្ទះក៏មិនសូវជាបានទៅដែរទាល់តែមានបុណ្យទានបានយើងបានទៅលេងផ្ទះណាក្មួយ ហើយធ្វើការនឹងក៏មិនសូវជាបានដេកពួនទេ។

កៈ អឺមចាស ម៉េចក៏ចឹង?

ខៈ យើងធ្វើការថែមម៉ោង ហើយណាមួយញ៉ុំក៏បាននឹងយប់ឡើងមិនសូវជាមិនគេងៗមិនលក់។

កៈ ចុះអ្នកមីងកាលនឹងធ្វើការខាងផ្នែកអីដែរ?

ខៈ មីងធ្វើខាងគណនីក្មួយ។

កៈ អូ មីងធ្វើខាង accounting កាលនឹងអ្នកមីងជួលផ្ទះគេនៅភ្នំពេញឬក៏មានផ្ទះជារបស់ខ្លួនឯង?

ខៈ អឺ មីងមានផ្ទះជារបស់ខ្លួនឯងនៅផ្សារថ្មី កាលនឹងមីងនៅជាមួយបង។

កៈ ចាស ដល់ពេលហើយបានដល់ជំនាន់អាពត!

ខៈ អូ អត់ទេក្មួយ កាលនឹងបែកជំនាន់អាពតហើយៗបានមីងធ្វើការនឹង បើកាលដែរជំនាន់ពលពតនឹងមីងទៅរស់នៅខេត្តកំពង់ធំហើយបានត្រឡប់មកភ្នំពេញវិញមករស់នៅទឹកល្អក់ ហើយមីងទាន់ចំជំនាន់លន់នលខ្លាំងជាង។

កៈ ហើយចុះស្ថានភាពកាលនោះអ្នកមីងអាននិយាយពីទុក្ខលំបាកដែលមាននៅក្នុងសម័យថាពិបានបែបណាខ្លះបានដែរទេអ្នកមីង?

ខ៖ ចាសក្មួយ កាលនោះមីងអាយុ១២ ឆ្នាំ
ហើយនៅក្នុងជំនាន់ពលពតពិបាកណាស់មិនស្រួលទេណាមួយមីងនៅក្មេងមិនសូវជាដឹងអីប៉ុន្មានទេ នៅស្ទើរកុមារហើយធ្វើការមិនអោយយើងទៅជួបឪពុកម្តាយទេ ធ្វើការនៅក្នុងការដ្ឋានហើយការដ្ឋានជំនាន់នោះ អីក្មួយមានស្គាល់ព្រៃឡង់ទេ?

ក៖ ចាសស្គាល់។

ខ៖ ចាស
នឹងក្មួយកាលនឹងមីងធ្វើការនៅក្នុងព្រៃឡង់នឹងហើយមិនដែលឃើញពន្លឺព្រះអាទិត្យទេ គេបង្ខាំយើងអោយធ្វើការអោយគេបែកបាក់ក្រុមគ្រួសារបងប្អូននឹង។

ក៖ ចាស!

ខ៖ អូ!
ក្មួយកំសត់ណាស់កាលសម័យនឹងប្រហែលជាសម័យម៉ាកក្មួយឯងអីនឹងអាចទាន់ដែរហើយៗមីងធំចំពេលពលពតនឹងម៉ងក្មួយ។

ក៖ ចាស ប្រហែលជាម៉ាក់ខ្ញុំនឹងអាចទាន់ដែរ

ខ៖ គាត់អាយុប៉ុន្មាន?

ក៖ ម៉ាក់ខ្ញុំគាត់អាយុ ៤៦ឆ្នាំហើយមីង។

ខ៖ អឹម ចឹងនៅមិនទាន់ជំនាន់ពលពតទេ។

ក៖ គាត់ទាន់ជំនាន់ពលពតមីងព្រោះម៉ាក់ខ្ញុំគាត់កើត១៩៧២។

ខ៖ អឹម!!

ក៖
ហើយខ្ញុំលឺម៉ាក់យាយប្រាប់ថាគាត់បានទាន់ជំនាន់លន់នលនឹងដែរហើយមានគេទំលាក់គ្រាប់បែកច្រើន នឹងមានរណ្តៅត្រង់សេពេញនឹងហើយមានជីករណ្តៅនឹងនៅពួនគ្រាប់បែកទៀត។

ខ៖ ចាសមានមែនកាលនឹង!

ក៖ ហើយចុះអ្នកកាលនឹងមានជីករណ្តៅធ្វើជាផ្ទះនៅទេ?

ខ៖ អឺ កាលណោះផ្ទះមីងនៅកណ្តាលភ្នំពេញ ហើយកាលនឹងមីងដូចជាអត់ជីករណ្តៅអីផងអូន។

ក៖ ចឹងគេអត់ទំលាក់គ្រាប់បែកទេហ៎មីង ឬមួយក៏គេទំលាក់គ្រាប់បែកតែតាមជនបទ?

ខ៖ ទេក្មួយកាលនឹងមីងសូវជាដឹងទេ តែគ្រាន់តែថានៅពេញដូចជាមិនឃើញមានរណ្តៅគ្រាប់អីផង។

ក៖ ចាស ព្រោះកាលនឹងគេចែកជាពីរផ្នែកមួយផ្នែកខាងទីក្រុងហើយមួយផ្នែកទៀតនឹងខាងជនបទហើយភាគច្រើនគេទំលាក់គ្រាប់តែតាមជនបទទេ។

ខ៖ ចាស ខ្ញុំអត់ដែលបានឃើញដែរនឹង!

ក៖ ចឹងកាលនឹងមីងនៅតែក្នុងផ្ទះទេន៍?

ខ៖ នៅផ្ទះ ហើយក៏ទៅរៀនអីចឹងទៀត។

ក៖ អូ នៅរៀនបានដែរ?

ខ៖ ចាស កាលនឹងនៅរៀនបានតើ។

ក៖ ចុះអ្នកមីងរៀននៅសាលាណាដែរ?

ខ៖ មីងរៀននៅសាលាសន្ធោមុខ។

ក៖ ចាស កាលមីងរៀននៅសាលាសន្ធោមុខនឹង មីងរៀនចប់ត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ មីងរៀនបានថ្នាក់ទី៧ ហើយចូលទី៦ បានបែកពីភ្នំពេញ។

ក៖ ហើយពេលមីងរៀននៅសម័យនឹងមីងមានដឹងថាគេរៀនចប់ត្រឹងថ្នាក់ណាដែរទេ ហើយគេប្រលងចេញនៅពេលណាដែរអ្នកមីង?

ខ៖ អឹមក្មួយ កាលសម័យនោះគេរៀនដេញថយក្រោយខុសពីសម័យនេះ គេចាប់ផ្តើមរៀនពីថ្នាក់ទី១២ រហូតដល់ថ្នាក់ទី១ ទំនើបជាតិបានចប់។

ក៖ ចាស!!

ខ៖ ប៉ុន្តែរៀនជំនាន់នោះមីងដឹងខ្លួនឡើង មីងចេះភាសាបារាំងម៉ង។

កៈ អូ! ដោយសារឪពុកម្ដាយបង្ហាត់ឬម៉េចដែរអ៊ុំ?

ខៈ អត់ទេគ្មានឪពុកម្ដាយណាបង្ហាត់ទេ នៅសាលាបង្រៀន។

កៈ នៅសាលាបង្រៀន?

ខៈ ចាស គេបញ្ចូលភាសាបារាំងនឹងចូលម៉ងកាលនោះមិនមានភាសាអង់គ្លេសទេ មានតែភាសាបារាំងរហូតដល់មីងអាចនិយាយភាសាបារាំងបានណា តែសព្វថ្ងៃនេះចង់ភ្លេចអស់ហើយតែបើរំលឹកអាចចេះឡើងវិញ។

កៈ ទាំងសរសេរ ទាំងស្ដាប់ ទាំនអាន និងនិយាយបានទាំងអស់ហ្អែសមីង?

ខៈ ចាស នឹងហើយក្មួយ ហើយកាលនឹងប៉ារបស់មីងធ្វើការនៅស្ថានទូតបារាំងចឹងពេលដែលគាត់មកផ្ទះគាត់និយាយជាមួយកូនក៏ភាសាបារាំង។

កៈ ចាស!!!

ខៈ ហើយជំនាន់លន់នលណាសក្មួយផ្ទះអ្នកណាមានទូរទស្សន៍មើល មានវិទ្យុស្ដាប់ មានកង់មានម៉ូតូកញ្ចាស់មួយនឹង គេជាអ្នកមានហើយ បើល្មមគ្មានទេ ហើយផ្ទះមីងចាត់ទុកថាជាអ្នកមានហើយព្រោះសួរគេទៅដល់ណាក៏គេស្គាល់ដែរ។

កៈ ចាស!

ខៈ ផ្ទះរបស់មីងនៅជិតផ្ទះជាគឹម អេង អឺ ក្មួយឯងកើតមិនទាន់ទេ ជា គឹមអេង នឹងជាមេប៉េអឹមស្រុកខ្មែរ។

កៈ ចាស!

ខៈ ហើយផ្ទះរដ្ឋមន្ត្រីស្ថាបនា ង៉ិន មានផ្ទះគយ និយាយផ្ទះអ្នកធ្វើការធំៗច្រើនណាស់នៅជាប់ៗផ្ទះមីងនឹងម៉ង។

កៈ ចាស ដល់ពេលជំនាន់ពលពតគេជំលៀសចេញផ្ទះនឹងចែកអោយគេអស់ទៅ?

ខៈ អឺ កាលនឹងមីងសួរជាដឹងដែរតែពេលេដែលមីងមកវិញផ្ទះនៅដដែល គ្រាន់តែថានៅសងខាងផ្ទះសុទ្ធតែព្រៃហើយយើងអត់ហ៊ានចូលនៅទេ គ្រាន់តែដីមីងនៅក្នុងភ្នំពេញនឹងមិនតិចទេ។

កៈ ចាស តែគេយកដីកាត់របបចែកគ្នាត្រូវហ្អែសមីង?

ខៈ ចាស ហើយកាលនឹងខ្ញុំមានដីពីរកន្លែង មួយកន្លែងនៅទឹកល្អក់
មួយកន្លែងទៀតនៅឬស្សីកែវ ដីទួលអស់លោក ក្មួយស្គាល់ងហ្អែស?

កៈ អូ ចាស ធ្លាប់លឺ!

ខៈ គ្រាន់តែនៅទួលអស់លោកដីមីងនឹងរស់នៅ២០គ្រួសារក៏បានដែរ។

កៈ ចាស ដីធំមីងមិនទៅនៅពេលដែលបែកពីពលពតដំបូង?

ខៈ យើងមិនហ៊ាននៅក្មួយចុះបើវាស្ងាត់ មានតិចគ្រួសារមែនទែនដែលទៅរស់នៅនឹង
ហើយកាលមីងចូលមកភ្នំពេញដំបូងនឹងមានតែជំនួយការវៀតណាម
ថាភ្នំពេញឡើងស្ងាត់ជ្រងំទៅណាស់ក្មួយមិនសូវមានមនុស្សនៅទេ ហើយសុទ្ធតែព្រៃ។

កៈ ចាសអ្នកមីង កាលនឹងគេជំលៀសមីងទៅណាដែរ?

ខៈ មុនដំបូងទៅនៅកំពង់ចាម ហើយដល់ក្រោយមកបានគេអោយទៅនៅកំពង់ធំ។

កៈ ចាស ហើយនៅក្នុងសម័យនឹងផងដែរគេបានប្រើមីងអោយធ្វើអីខ្លះដែរ?

ខៈ គេប្រើមីងអោយជីកប្រឡាយ លើកទំនប់ ហើយកាលនឹងមីងនៅតូចដែរនឹង
ប្រហែលប៉ុននឹងកូនមីងមីពៅនឹងអាយុទើប១២ ឆ្នាំ
ហើយមីងកាលនោះស្គមសឹងថាដើរគេបែងជើងតែតិចនឹងក៏ដួលដែរហើយគេមិនអោយយើង
ហូបគ្រប់គ្រាន់ទៀត បើបង្គីវិញធំៗណាស់
ទោះរែកក៏រែកមិនរួចដែរគ្រាន់ឃើញបង្គីនឹងខ្លាចបាត់ហើយចុះវាធំៗពេកណាក្មួយ
ហើយពេលដែលគេដាក់ដីក្នុងបង្គីអោយនឹងជាន់អោយហាប់ហើយត្រួតពីលើនឹងទៀត
ដល់ហើយ ក្មួយឯងស្គាល់ទំនប់៧ មករា ហ្អែស?

កៈ ចាស ស្គាល់មីង!

ខៈ ចាស ទំនប់នឹងហើយដែលពួកមីងនឹងជីកយកដីទៅដាក់ធ្វើជាទំនប់នឹង
កសាងទំនប់នឹងឡើងណាក្មួយនិយាយថាវេទនាទំរាំនឹងលើកទំនប់មួយនឹងហើយមិនងាយទេ
ណាក្មួយ សម័យមិនអាចូកដូចសម័យនេះណា
ប្រើកំលាំងបាយសុទ្ធសាធហើយបើយើងមិនធ្វើទេគេជេរស្តី គេប្រមាថសព្វគ្រប់ទៅ
ហើយមិនចឹងគេយកទៅកសាង

ហើយបើគេយកទៅកសាងហើយគ្មានសង្ឃឹមថានឹងរស់ទេភាគរយដែលរស់មានស្ដួចស្ដើងណាស់
ចឹងហើយចេះតែទ្រាំទៅធ្វើការហាត់សឹងតែថាដាច់ខ្យល់ស្លាប់ម្ដងៗណាដែលវាក្ដៅនឹងក៏ក្ដៅ
ហើយណាអាជីក្នុងបង្គីនឹងក៏វាធ្ងន់ម្នាក់ៗទាំងគេទាំងយើងចេះតែធ្វើទៅមិនហ៊ានមាត់មិនហ៊ានកអីទេ។

ក៖ ចាសមីង ហើយចុះបើគេប្រើអោយធ្វើការធ្ងន់ៗចឹងមីងធ្លាប់ឈឺដែរទេ?

ខ៖ អូ និយាយពីរឿងឈឺនឹងលេខមួយហើយ មីងឈឺនឹងថាតែមិនរស់ផងទេ
សំណាងហើយដែលអាចបានមកដល់សព្វថ្ងៃនេះហ៏ ក្មួយ
ពេលនឹងមីងឈឺខ្លាំងណាស់ហើយស្រាប់ពេលក្រោកឡើងនៅសងខាងមីងសុទ្ធតែខ្មោច
គេគ្របកំណាត់ស ទាំងអស់ ថាកាលនោះដប់នាក់មានម្នាក់ទេដែលនៅរស់នោះ។

ក៖ ចាស ហើយកាលនឹងអ្នកមីងឈឺអីដែរ?

ខ៖ កាលណោះអាសន្នរោគ!

ក៖ រាគហ្មែសមីង?

ខ៖ ចាសនឹងហើយក្មួយ រាគផងក្អួតផង ស្លាប់ច្រើនណាស់ជំនាន់ពលពតនឹង។

ក៖ ហើយអត់មានអ្នកជួយសង្គ្រោះទេហ៏ អ្នកមីង?

ខ៖ អឹម ក្មួយ វាដូចថាមនុស្សវាច្រើនពេកមិនដឹងថាជួយអ្នកណា ទុកអ្នកណា
ជួយមិនក៏មិនទាន់ដែរព្រោះជំងឺអាសន្នរោគនឹងចាប់ឡើងភ្លាមៗម៉ងដូចថាយើងត្រៀមខ្លួនមិនទាន់ណា។

ក៖ ចាស ចឹងអ្នកមីងសំណាងមែនទែនដែលអាចរស់រានមានជីវិតមកបាន។

ខ៖ ចាសសំណាងមែននឹងក្មួយ ចេះបានដឹងខ្លួនផុងពីសេចក្ដីស្លាប់មកបាន
ហើយបានមេពលពតនឹងវាឃើញមីងតូចជាងគេហើយស្គមទៀតហើយវាហៅមីងតែម៉ែចាស់ៗទេ នៅក្មេងទេអាយុនឹងនៅតិចដែរ
តែយើងស្គមកំព្រឹងហើយអត់មានអីហូបនោះក្មួយហូបតែផ្លែល្ពាក់និងផ្លែគុយ
ហើយហោតុតែឃ្លានណាស្អីក៏ហូបហើយមិនដឹងពុលមិនពុលទេ មានស្គាល់ផ្លែល្ពាក់ទេ?

ក៖ ចាស ខ្ញុំអត់ស្គាល់ផង!

ខ៖ អឹម អត់ស្គាល់ផ្លែល្ពាក់ហ្អែស?

ក៖ អត់ស្គាល់ផង!

ខ៖ អឹមអត់ស្គាល់ផ្លែល្ពាក់!

ក៖ ផ្លែនឹងនៅក្នុងព្រៃហ្អែស មីង?

ខ៖ និយាយទៅដើមនឹងវាដុះក្នុងព្រៃ តែនៅភ្នំពេញក៏មានលក់ដែរ។

ក៖ ដើមវាដូចដើមផ្តៅនឹងមែនមីង?

ខ៖ ដើមវាដូរដើមផ្តៅនឹងតែវល្លិ៍ៗតូចជាងដើមផ្តៅហើយមានបន្លា។

ក៖ ចាស ខ្ញុំធ្លាប់លឺតែមិនដែលឃើញផងមីងមិនដឹងថារូបរាងម៉េចផង។

ខ៖ អត់ដែលឃើញហ្អែស?

ក៖ ចាស ដើមដែលគេយកធ្វើទូនឹងមែនមីង?

ខ៖ អត់ទេ មិនមែនទេ ចុះក្មួយឯងដែលទៅញុំអីនៅកាំបូឌីយ៉ាណាទេ?

ក៖ ដូចជាអត់ដែលទៅផងមីង។

ខ៖ អ៊ី នៅនឹងគេមានលក់ផ្លែល្ពាក់នឹង អោយតែដល់ខែធ្លាក់ភ្លៀងល្ពាក់នឹងវាចាប់ផ្លែហើយ ចុះដែលញុំផ្លែគុយទេ?

ក៖ ចាស ធ្លាប់មីង!

ខ៖ អើ គុយនឹងផ្លែល្ពាក់អោយទេកន្លែងណាមានគុយដឹងតែមានល្ពាក់ហើយ

ក៖ ចាស់ មីង!

ខ៖ ផ្លែធំៗ ខ្មៅៗរលោងៗ ហើយឆ្ងាញ់ណាស់។

ក៖ ចាស ហើយកាលជំនាន់នឹងម៉េចដែរទៅអ្នកមីង?

ខ៖ ហ៊ើយ ក្មួយហើយកាលជំនាន់នោះដើរតែទាក់ស្មៅក៏ដួលដែរ បបរមួយខ្ទះនឹងឃើញសុទ្ធតែទឹក មានអង្ករតែពីរបីកំប៉ុងទេ ហើយគេមានលាយគល់ចេក គេលាយស្លាបចង្វា ក្មួយឯងស្គាល់ស្លាបចង្វាទេ?

កៈ អត់ស្គាល់ផងមីង!

ខៈ អឺម អត់ស្គាល់ ស្គាល់គល់ចេកទេចុះ?

កៈ ចាសគល់ចេកស្គាល់មីង!

ខៈ អើ នឹងបបរគេលាយគល់ចេកគល់អីនឹង អោយយើងហូបដូចបបរអោយជ្រូកចឹងក្មួយគ្មានខុសអីនឹងបបរជ្រូកតិចទេ តែបើយើងមិនហូបមានកំលាំងឯណាធ្វើការចឹងហើយទាំងគេទាំងយើងចេះតែទ្រាំលេបទៅអោយតែរស់ៗទៅ។

កៈ ចាសអ្នកមីង ហើយគេអោយអ្នកមីងហូបប៉ុន្មានពេលដែលក្នុងមួយថ្ងៃ?

ខៈ ក្នុងមួយថ្ងៃគេអោយយើងហូបតែពីរពេលទេក្មួយពេលព្រឹកនិងពេលល្ងាចងើបទៅធ្វើការតាំងពីព្រលឹមចឹងទៅពេលថ្ងៃអោយបបរមួយចាន ហើយពេលល្ងាចនឹងទំរាំតែនឹងបានឡើងមកពីធ្វើការវិញហូបបបរនឹងខ្វងម៉ោង១០ ម៉ោង១១យប់នឹងហើយក្មួយ។

កៈ តែពីរពេលទេមីង?

ខៈ ចាស ហើយពេលយប់នឹងស្ទួងទាល់តែម៉ោងប្រាំបួនម៉ោងដប់ទើបគេអោយយើងមកកន្លែងមកការដ្ឋាននឹងណាហើយទំរាំតែនឹកមកដល់ការដ្ឋានទំរាំតែនឹងបានសំរាកម៉ោង១១ ១២ឯណោះចូលដេកនឹងក៏យូរហើយក្រោកនឹងក៏លឿនដែរមិនអោយឯងបាននៅតំរង់ខ្លួនដូចក្មេងសម័យនេះដេកម៉ោង៦ ម៉ោង៧បានក្រោកទេ បើនៅសម័យនោះហ៊ានតែធ្វើចឹងបែបស្លាប់បាត់តាំងពីយូរហើយមិនរស់ទេ។

កៈ (សើច) ចាស ក្មេងសម័យនេះរាងគេងទ្រមុកតិច។

ខៈ ក្មួយហូបមិនគ្រប់មិនគ្រាន់ហើយប្រើទាល់តែបាក់កំលាំងធ្វើបាបខ្លាំងណាស់ជំនាន់នឹង បើអ្នកដែលសុខភាពគេល្អទៅចេះតែតាទល់នឹងវាសនាទៅបើអ្នកណាទ្រាំមិនបានទេទៅក៏ឈឺស្លាប់ទៅក៏មានដែរ តែថាទៅស្លាប់ដោយសារជំងឺក៏ច្រើនដែរ តែដើមហេតុនឹងគឺមកពីបង្ខំអោយធ្វើការខ្លាំងពេកនឹងឯងហើយហូបនឹងក៏មិនជាពេញពោះ ចំណែកឯថ្នាំនឹងក៏មិនដឹងជាស្អីមានតែសំបកឈើ

និងថ្នាំអាចម៍ទន្សាយនឹងអាគ្នាឈឺម៉េចក៏ប្រើតែថ្នាំតែប៉ុន្មានមុខនឹងដូចតែនឹង ហើយគ្រូពេទ្យអីនឹងគ្មានជំនាញច្បាស់លាស់ទេដូចថាចេះតែល្មមៗណាក្មួយ ពេលខ្លះទៅដាក់ថ្នាំជ្រុលទៅប្រកាច់ប្រកិនទៅ ខ្លះទៅក៏ស្លាប់ទៅ ហើយខ្លះទៀតទៅក៏រស់ទៅ។

ក៖ ហើយអ្នកមីងកាលនឹងមីងគេងគ្នាប៉ុន្មាននាក់ដែរ?

ខ៖ (សើច) ក្មួយមួយការដ្ឋាននឹងមានគ្នាច្រើនណាស់ មួយហែរចឹងទៅហើយដេកតំរៀបជួរគ្នាហូរហែរចឹងទៅក្មួយ មិនមានអីគ្រែត្រឹមត្រូវដូចក្មេងសម័យនេះទេរកតែខ្នើយអោយស្រួលកើយនឹងសឹងមិនមានផង ដេកតំរៀបគ្នាទៅទាំងគេទាំងយើងនឹងទៅ។

ក៖ ចាសអ្នកមីង ប្រហែលជា២០ ទៅ៣០ នាក់ដែរទេ?

ខ៖ អឺម អត់ទេប្រហែលជាចូលរយនាក់ហ៍ក្មួយមនុស្សច្រើនណាស់ព្រោះការដ្ឋានគេធំដែរដាក់បានមនុស្សច្រើនវាធ្វើការដ្ឋានអោយធំៗទៅស្រួលដាក់មនុស្សបានច្រើនហើយកំលាំងធ្វើការក៏ច្រើដែរកាលណាកំលាំងធ្វើការច្រើនធ្វើការលឿនចឹងគេលើកជាក្រុមនឹងជាក្រុមគំរូអោយក្រុមផ្សេងៗនឹងមើលជាគំរូ។

ក៖ ចាស ចុះកាលនោះមីងមានដែលធ្លាប់ឃើញគេយកមនុស្សទៅសំលាប់ដែរទេ?

ខ៖ មីងអត់ដែលឃើញផ្ទាល់នឹងភ្នែកទេគ្រាន់តែថា យើងនៅការដ្ឋានចឹងទៅនៅសុខៗស្រាប់តែគេថា មោះសមៈមិត្តនេះទៅនោះមួយភ្លេត អោយតែគេហៅចឹងដឹងតែគេយកទៅវ៉ៃចោលហើយ តែយើងទោះដឹងក៏ដោយនៅមាត់អោយស្ងៀមធ្វើតែមិនដឹងមិនលឺទៅបើចង់រក្សាជីវិតអោយគង់។

ក៖ ចុះអ្នកមីងភ័យតក់ស្លុតដែរទេពេលដែលឃើញមិននៅមុខៗចឹង?

ខ៖ ភ័យនោះភ័យលែងនិយាយហើយម្នាក់ៗមិនមែនមានតែមីងទេដែលភ័យនោះគ្រប់តែគ្នានឹងតែមិនដឹងធ្វើម៉េច គេមិនប្រាប់យើងទេតែយើងចាំនាំគ្នាសង្កេតមើលណាហើយម្នាក់អោយតែឃើញចឹងភ័យឡើស្វាយមាត់អស់ហើយ។

កៈ ចាស បើលេងយកទៅសំលាប់ផុយៗចឹងអី។

ខៈ ចុះយើងធ្វើការជាមួយគ្នាចឹងយើងមិនដឹងហើយយើងស្គាល់គ្នាទៀតនុះ តែគេហៅចឹងហើយដឹងតែគេយកទៅវៃចោលហើយពេលគេយកទៅបាត់ចឹងនាំគ្នានិយាយគ្នា ហើយណាស់តែក៏មិនបញ្ចេញសកម្មភាពអីចំឡែកទេ ព្រោះបើគេចាប់បានច្បាស់ជាបានទៅមួយទៀតមិនខាតទេ តែលួចនិយាយគ្នាស្ងាត់ៗនឹងទៅ។

កៈ ហើយទៅបាត់រហូតទៅ?

ខៈ ចាស បាត់រហូតអាណិតណាស់ក្មួយ មួយភូមិអីនឹងនៅសល់តែពីរគ្រួសារអីទេវាយកទៅវៃចោលឡើងស្ងាត់ភូមិណាស់។

កៈ ចាស ចឹងកាលនឹងមីងភ័យទេ?

ខៈ ភ័យក្មួយភ័យខ្លាំងណាស់ មីងចេះរស់មកបានណា យប់នេះយកអ្នកនេះ ហើយយប់បន្ទាប់យកអ្នកនោះគ្មានថាថ្ងៃណាដែលថាវាមិនយកមនុស្សទៅវៃចោលទេថារាល់ថ្ងៃហើយមិនដឹងថាយកទៅវៃចោលឯណាទៀតណាអត់ដឹងសោះ។

កៈ ចាស ហើយកាលនឹងនៅតូចទៀត!

ខៈ នឹងនៅតូចមិនដឹងរត់ទៅណា បើរត់ចូលព្រៃខ្លាចខ្លាស៊ី។

កៈ ចុះចំណែកគ្រួសារអ្នកមីង កាលនឹងគេជំលៀសទៅនៅជិតគ្នាឬក៏នៅឆ្ងាយពីគ្នា?

ខៈ នៅនឹងទាំងអស់គ្នាអូន!

កៈ ចាស ពួកគាត់មើងថៃមីងបានដែរទេកាលនឹង?

ខៈ ហើ៎យ ក្មួយមួយឆ្នាំនឹងនៅមិនទាន់បានឃើញមុខគ្នាម៉េងផង។

កៈ តែនៅភូមិជាមួយគ្នា!

ខៈ នឹងនៅភូមិជាមួយគ្នាតែការដ្ឋាននឹងនៅឆ្ងាយៗពីគ្នា គ្មានពេលមកជួបជាមួយឪពុកម្ដាយទេក្មួយ នៅឆ្ងាយៗណាស់។

កៈ ចាស បែកគ្នាតាំងពីជំលៀសរហូតដល់ដាច់ពលពតទើបមីងបានជួបជុំគ្រួសារវិញ?

ខ៖ ចាសក្មួយ ពេលណានឹកម៉ែនឹកឪ យប់ឡើងដេកយំ
មានថ្ងៃមួយនោះមីងលួចទៅរកម៉ែទាំងយប់ ហើយពេលទៅវិញជាប់កងពិសេស គេវ៉ៃ
គេធ្វើបាប កាលនឹងលួចទៅគ្នាដប់អ្នក ហើយអ្នកដែលធំៗគ្នាវ៉ៃ ហើយចំណែកមីង គេអត់វ៉ៃទេ
តែគេអោយធ្វើការតាំងតែពីម៉ោង ៦ព្រឹង រហូតដល់ម៉ោង ៦ កន្លះល្ងាចបានគេអោយហូបបបរ
ឡើងសន្លប់ក្នុងស្រែក៏មានដែរ កំពុងតែស្ទូងនឹងដួលទៅតែម៉ងទៅ។

ក៖ អឹម ចុះគេមាននាំមីងទៅមន្ទីរពេទ្យទេ?

ខ៖ កាលនោះគ្មានអ្នកណាយកទៅពេទ្យអីទេ
គេលើកដាក់លើភ្លឺស្រែទៅហើយនាំគ្នាច្របាច់ដៃជើងទៅ អ្នកខ្លះនឹងក៏ដក់សក់អោយទៅ
ហើយឈ្លីក្បាលអោយទៅអីទៅក៏ដឹងខ្លួនឡើងម៉ោហើយក៏ធ្វើការបន្តទៀតទៅក៏មិនជាហ៊ានជួ
យណាប៉ុន្មានដែរតែមិនស្រួលមួយក្រុមនឹងត្រូវគេពិន័យទាំងអស់គ្នាមិនខានទេ
ថាវាឃោរឃៅខ្លាំងណាស់ទៅណាក្មួយ។

ក៖ ចាស ចុះកាលពីពេលដែលមីងឈឺក្នុងពេលដែលកើតអាសន្នរោគនឹង
គ្រូពេទ្យគេបានអោយថ្នាំអីអោយមីងលេបដែរ?

ខ៖ កាលនឹងហ្អែស?

ក៖ ចាស!

ខ៖ មីងមិនដឹងថាជាថ្នាំអីទេ ឃើញតែទឹកក្រហមៗ ដាក់ចូលក្នុងដបទឹកក្រូចទេ?

ក៖ ចាស ស្គាល់!

ខ៖ នឹង មីងដឹងថាជាថ្នាំអីទេ ឃើញតែក្រហមៗនឹង។

ក៖ ហើយទៅគេអោយមីងផឹកទឹកនឹងទៅ?

ខ៖ អត់ទេ ចាក់ក្មួយ!

ក៖ អឹម ចាក់វិញន៍ ហើយចុះកាលនោះមានម្ជុលអីដូចយើងនៅសម័យនេះទេអ្នកមីង?

ខ៖ មានដូចគ្នានឹងសម័យនេះដែរក្មួយ
តែមានតែម្ជុលទេដែរដូចបើថ្នាំវិញចាក់ហើយងាប់ព្រោងព្រៀត ភាគច្រើននឹងគឺស្លាប់ម៉ង។

ក៖ ហើយចុះអ្នកមីងមានចាំទីតាំងពេទ្យនឹងដែរទេ?

ខ៖ ពេទ្យនឹងរាល់ថ្ងៃនៅរស់តើ!!

ក៖ អូ គាត់នៅរស់ដែរ?

ខ៖ ចាស មីងទៅអរគុណគាត់ទិញសារុងអីជូនគាត់អីចឹងទៅ។

ក៖ ចាស ហើយចុះសព្វថ្ងៃនេះគាត់អាយុប៉ុន្មានហើយមីង?

ខ៖ មីងសួរជាដឹងដែរក្មួយ មិនដឹងថាគាត់អាយុប៉ុន្មានទេ តែដឹងតែថាគាត់ចាស់ណាស់ហើយប្រហែលជាចូលខ្ទង់៧០ អីហើយមើងទៅនោះ។

ក៖ ចាស ឃើញថាអ្នកមីងសំណាងមែនទែន ងើបមកមិនមានអ្នកណាគេរស់!

ខ៖ ចាស ងើបឡើងមានតែមីងម្នាក់ដែលមានជីវិតសល់ប៉ុន្មានទៀតដេកស្ដូកស្ដឹង។

ក៖ ចាស ហើយចុះមានចងចាំអ្វីដែលមីងគិតថាពិបាកជាងគេនៅក្នុងជីវិតរបស់អ្នកមីងហើយធ្វើអោយអ្នកមីងមិនអាចបំភ្លេចវាបាន?

ខ៖ អ្វីដែលគ្រប់ពេលមីងនឹកឃើញមីងឈឺចាប់នោះ គឺពេលដែលមីងលួចរត់ទៅលេងម៉ែហើយពេលមកវិញជាប់ក្នុងកងពិសេសនឹងគេអោយមីងរត់ហើយគេវ៉ៃពីក្រោយ តែមីងនឹងគេមិនវ៉ៃទេចេះតែរត់ទៅដួលផ្កាប់មុខក៏មានអីក៏មានដែរ ហើយកងពលពតនឹងគេលើកយើងហើយជួយបោសទ្រូងអោយ ចុះបើដួលទៅវាប្រលាក់ភក់ប្រលាក់ដីស្រមេះស្រម៉ូសពេញទាំងខ្លួននឹង ហើយពេលងើបមកចឹងក៏រត់ទៅទៀតទៅ ហើយពេលចុះស្ទូងចឹងដែរឈ្លើងប៉ុនៗកដៃក្មួយឈ្លើងណា មីងប្រកាច់ពេញស្រែទាំងអស់ភ័យណាស់ចុះយើងខ្លាចនោះក្មួយពេលនឹងមេកងមិនមេកងមើលក៏មើលទៅបើយើងខ្លាចហើយធ្វើម៉េចអ្នកណាទៅទ្រាំអោយវាខាំនោះ។

ក៖ ហើយបន្ទាប់ពីនឹង តើមានគេធ្វើបាបមីងអីទៀតដែរឬទេអ្នកមីង?

ខ៖ ក្មួយហើយ ពេលយប់ឡើងចឹងគេអោយយើងទៅអង្គុយយាមខ្លា សត្វខ្លានឹងណា។

ក៖ ចាស!

ខ៖ ព្រោះខ្លានឹងចង់ប៉ុនៗគោ បើក្មួយឯងឃើញចង់ញាក់សាច់ហើយទៅគេអោយយើងនឹងទៅអង្គុយចាំយាមខ្លាព្រោះខ្លានឹងវាចូលមកនឹងចង់ស៊ីមនុស្ស

ខ្លាជំនាន់ពលពតអូន ភ្នែកខៀវៗងងឹតចំណែកយើងនៅត្រើយម្ខាងអូរ
កាលណាឃើញវាចឹងត្រូវប្រញាប់គោះត្រដោកហើយត្រដោកនឹងដែរគេដាក់វាសំរាប់គោះដា
ស់យើងអោយភ្ញាក់ពេលមានអាសន្នអីចឹងណា
ហើយម្នាក់ៗអោយតែលឺសំលេងត្រដោកនឹងត្រូវម្នីម្នារប្រញាប់ងើបមកទាំងអស់គ្នានឹងបើមិនចឹ
ងខ្លាស៊ីហើយ។

កៈ អូយ សាហាវណាស់ន៍!

ខៈ អឹម
ក្មួយបើដើរចូលព្រៃណាតែហ៊ានដើរហួសពីបីម៉ែត្រទៅប្រាំម៉ែត្រដឹងតែខ្លាហែកស៊ីហើយ
មានណាមានខ្លានឹងហែកមនុស្សស៊ីណាក្មួយ។

កៈ ម៉េចចឹងមីងមកពីគាត់ចូលព្រៃជ្រៅពេកហ្អែស?

ខៈ ចាស កាលនឹងគេប្រើអោយទៅបោចដើមល្ពាក់ណាស់ក្មួយ
ហើយកាលនឹងគេដាក់ផែនការណ៍ក្នុងម្នាក់អោយបានប៉ុន្មានសរសៃរទេកាលនឹង
ហើយបើសិនណាយើងបោចមិនបានគេធ្វើទារុណកម្មយើង
ដល់ចឹងអាដើមល្ពាក់នឹងវានៅក្នុងព្រៃជ្រៅទើបមានដើមល្ពាក់ដុះនៅក្នុងព្រៃឡង់នឹងណាក្មួយ
ទាល់តែយើងចូលទៅជ្រៅទើបមានអារាក់ៗនៅជិតមាត់ព្រៃនឹងមិនសូវមានទេ
ហើយយើងមានខំបោចអោយគ្រប់ផែនការណ៍គេនឹងទៅបើមិនគ្រប់ទេគេធ្វើបាបយើង។

កៈ ចាស បើមិនបានគេធ្វើបាបហើយបើចូលក្នុងព្រៃមានខ្លាទៀត។

ខៈ ចាស ម្នាក់ៗក្មួយបន់ដូនបត់តាភ្នែកនៅកញ្ជឹងក ណាវាខ្លាចខ្លា
ណាវាខ្លាចថាមិនគ្រប់ចំនួនអោយគេខ្លាចថាគេវ៉ៃធ្វើបាប
ម្នាក់ៗមិនដឹងថាខ្លួនស្លាប់ថ្ងៃណាទេហើយបើស្លាប់មានតែពីរទេគឺគេយកទៅសំលាប់និងខ្លាវា
ស៊ីនឹងម៉ង។

កៈ ហើយចុះមីងកាលនឹងម៉េចក៏មិនទៅជាក្រុមទៅ?

ខៈ
នឹងអូនអាពីពេលដែលទៅនឹងយើងទៅជាក្រុមតែដល់ចូលក្នុងព្រៃយើងមិនមែនចូលជាក្រុម
ណាត្រូវបំបែកគ្នារកចែកគ្នារកទៅ។

កៈ ចាស ហើយចុះពេលដែលទៅនឹងយើងមិនមានកាំបិតទៅជាមួយដែរ?

ខ៖ អត់ទេ គេមិនមានកាំបិតអោយយើងទេក្មួយទៅចឹងទៅដើរបោចនឹងដៃទៅហើយដៃជើងនឹងខ្ទេចខ្ទីអស់ហើយមុតបន្លាឡើងហើមទៅក៏មានដែរ។

ក៖ ហើយចឹងបោចនឹងដៃ?

ខ៖ ចាស បោចនឹងដៃនឹងណាក្មួយ។

ក៖ ហើយចឹងមិនមុតដៃស្លាប់ហើយ!

ខ៖ អូយ! ក្មួយអារឿងមុតដៃនឹងវាលែងនិយាយហើយ គេគ្នាអោយកាំបិតយើងទេវាដឹងតែថាមកវិញត្រូវតែបានដើមល្ពាក់នឹងមកអោយវាអោយចំនួនដែលគេកំណត់នឹងទៅ បើមិនគ្រប់ទេគេធ្វើទារុណកម្មយើងហើយ។

ក៖ ចឹងដូចប្រើទៅអោយខ្លាស៊ីចឹងនឹង?

ខ៖ ចាស អ្នកឯងមានសំណាងល្អទៅក៏មានជីវិតត្រឡប់មកវិញម៉ោបើអ្នកឯងគ្មានសំណាងទេក៏ត្រូវខ្លាស៊ីនឹងទៅ ពេលមកជុំគ្នាបាត់ពីរនាក់ស្រាប់តែទៅរកមើលឃើញតែស្នាមឈាមហើយនិងសារុងរលេះរលួយអស់មើលមិនស្គាល់ថាជាអ្នកណាផង ខ្លាធំៗណាស់ជំនាន់នឹងនោះ។

ក៖ ហើយចុះកាលនឹងមីងឃើញខ្លានឹងផ្ទាល់ម៉ងហ្អែស?

ខ៖ ចាស ឃើញផ្ទាល់ណាក្មួយចុះបើយើងយាមនុះ ហើយភ្នែករបស់វានឹងធំៗខៀវដូចអំពូលភ្លើងចឹង ហើយវាយំនឹងដូចឆ្មាចឹងក្មួយតែគ្រាន់តែថាសំលេងវាធំជាងឆ្មា ហើយកាលនឹងក្នុងមួយវេទអ្នកចាំយាមខ្លានឹងក្នុងវេទមានគ្នាបីអ្នកហើយមិនមានទេខ្លាទេ អោយតែពេលល្ងាចឡើងឆ្កែចចកនឹងលូនោះលូគ្មានល្ហែទេ ស្គាល់ឆ្កែចចកទេ?

ក៖ ស្គាល់វាដូចឆ្កែធម្មតាតែនៅក្នុងព្រៃ។

ខ៖ នឹងឆ្កែចចកមាននៅក្នុងព្រៃច្រើនណាស់ អោយតែល្ងាចម៉ោង៨ម៉ោង៩នឹងវាផ្ដើមលូហើយពាល់យប់ស្ងាត់ឈឹងលឺតែសំលេងឆ្កែចចកលូទៅ តែអាលូរមិនដឹងថាទៅណាអស់។

ក៖ បាត់ទៅបណ្ដើរៗ

ខ៖ មិនមែនបាត់បណ្ដើរៗទេក្មួយបាត់អស់តាម៉ង!

ក៖ ហើយកាលនឹងមីងឃើញខ្លានឹងផ្ទាល់ភ្នែកហ្អែស?

ខ៖ ចាស ឃើញផ្ទាល់ភ្នែកក្មួយ មីងគេអោយនៅយាម។

ក៖ នៅតូចៗផងគេអោយយាមខ្លាខ្លាចស្លាប់ហើយ។

ខ៖ អួយ ក្មួយពេលឃើញវានិយាយថាខ្លួននឹងញ័រអស់ហើយ ចុះបើខណ្ឌតែអូរនៅកណ្ដាលតូចមួយនឹង។

ក៖ ចាស តែវាអត់ហ៊ានឆ្លង?

ខ៖ វាអត់ហ៊ានឆ្លងទេព្រោះមានទឹក ហើយទឹកនឹងជ្រៅទៅក៏មិនដឹងទេ

ក៖ ហើយចុះទឹកនឹងមានកំពើទេមីង?

ខ៖ ចាស ប្រហែលមានដែរនឹងក្មួយបើអូរនឹងវែងដែរហើយណាមួយអូរនឹងមិនបានជាតូចអីប៉ុន្មនាទេ។

ក៖ ចាស ហើយពេលឃើញខ្លាចឹងមីងគោះត្រលោកទៅ?

ខ៖ ចាស គោះត្រលោកដាស់គ្នីដាស់គ្នាទៅ ពេលណាយើងដើបឆូរឆរទៅវារត់ទៅបាត់ហើយ កាលនឹងអាយុ១២ ១៣ឆ្នាំនឹងកំពុងពេញដេកតែដេកនឹងមិនដែលបបានឆ្អែតម្ដងណាទេ ក្រចូលដេកហើយគេដាស់ពីព្រលឹមទៅស្ទូងស្រូវទៀត មិនដែលថាមានពេលសំរាកម៉េច? ផុតពីស្ទូងដកផុតតែពីដកស្ទូងគ្មានពេលល្ហែទេ មិនក្មេងសម័យនេះស្រួលមិនស្រួលនឹងមិនចេះទាំងដកស្ទូងម៉េចផង។

ក៖ ហើយចុះក្រៅតែពីរឿងចងចាំអាក្រក់ៗ និងបទពិសោធន៍នឹង អ្នកមីងចងចាំក៏ដូចជាបទពិសោធន៍អីល្អៗនៅក្នុងជីវិតរបស់អ្នកមីងដែរឬទេ?

ខ៖ បទពិសោធន៍ល្អៗហ្អែស?

ក៖ ចាស!

ខ៖ ការចងចាំល្អៗនឹងមីងត្រេកអរមែនទែនដូចថាពេលដែលយើងចេញមកមានការងារធ្វើអីចឹង ណាក្មួយ ជាពិសេសកាលដែលមីងធ្វើការនៅកាំបូឌីយ៉ាណានឹង។

ក៖ ចាស!

ខ៖ ដូចយើងនៅលើឋានសួគ៌ចឹង យើងបានធ្វើការងារល្អមិនចុះកំលាំង
យើងបានហូបចុកគ្រប់គ្រាន់ណាក្មួយ
នឹកឃើញជំនាន់ពលពតជុំគ្នាចឹងទៅនិយាយគ្នាទៅសប្បាយចឹងទៅ។

ក៖ ចាស ហើយក្រៅពីនេះអ្នកមីងមានបទពិសោធន៍អីទៀតដែរទេ?
បទពិសោធន៍ល្អមីងចងចាំហើយធ្វើអោយមីងសប្បាយចិត្តណាស់?

ខ៖ កាលនឹងមីងធ្វើការរោងចក្រកាលនឹងមីងអាយុ១៥ឆ្នាំហើយ។

ក៖ ចាស!

ខ៖ ធ្វើការរោងចក្រលីដែកក្មួយ ដែកធំៗណាស់
លីដែកបណ្ដើរយើងចូលរៀនបណ្ដើរដល់ពេលហើយគេជ្រើសរើសយកបុគ្គលិកអោយចូលធ្វើការនៅកាំបូឌីយ៉ាណាលើកដំបូង។

ក៖ ចាស!

ខ៖ ហើយទៅមីងក៏ទៅប្រលងដល់ពេលទៅប្រលងធ្លាក់
ហើយទៅនឹកឃើញអស់សង្ឃឹមហើយតែចេះតែរៀនទៀត ដល់ពេលហើយគេមកតាមដល់ផ្ទះ
គេថាបងអ្នកគ្រប់គ្រងអោយហៅបងឯងទៅ
ក៏ទៅហើយទៅដល់គេអោយយើងធ្វើតេស្តម្ដងទៀត ធ្វើតេស្តភាសាអង់គ្លេស
តែយើងចេះនោះភាសាបារាំង
អង់គ្លេសនឹងចេះដែរតែបើប្រកបទៅវាទៅជាចេញជាភាសាបារាំង។

ក៖ ភាសាអង់គ្លេស និងភាសាបារាំងស្រដៀងតែគ្នា!

ខ៖ ចាស វាទៅជាចឹងវិញតែបើបារាំងតែម៉ងចេះ ហើយទៅធ្វើតេស្តធ្លាក់តែវគ្គប្រកបនឹងមួយ
ដល់ក្រោយមកបានគេអោយជាប់ តែពេលដែលជាប់នឹងគេមើលកំពស់យើង
គេមើលរូបរាងយើង ហើយកន្លែងមីងនឹងគេរើសយកតែអ្នកណាស្អាតៗទេ
អ្នកជាប់កន្លែងនឹងដំបូងគេវាស់កំពស់យើងយកចាប់ពី
១៦០សង់ទីម៉ែត្រឡើងបើសិនយើងកំពស់តែ១៥៩សង់ទីម៉ែត្រក៏គេមិនយកដែរ
ហើយមីង១៦១សង់ទីម៉ែត្រគេក៏ព្រមអោយចូលលធ្វើតេស្ត
ហើយធ្វើតេស្តនឹងអ្នកមកសំភាសន៍យើងនឹងច្រើនគ្នាច្រើនជនជាតិតែគេសួរយើងតែភាសាអង់

គ្លេសមួយនឹងទេ តែគេនិយាយកាច់តុងណាស់ពិបាកស្តាប់ បើសិនណាជាជនជាតិអង់គ្លេស និងជនជាតិអាមេរិកពេកដែលគេនិយាយយើងស្តាប់បាន តែបើជនជាតិចិនអីនឹង ហើយក្អួយអើយតុងវាសាហាវណាស់ពិបាកស្តាប់ណាស់មិនដឹងវានិយាយអីទេស្តាប់គ្មានបានទេ មិនដឹងថាវានិយាយអី។

ក៖ កាលនឹងមីងដាក់ខាងផ្នែកអីដែរ?

ខ៖ ដំបូងឡើយមីងដាក់ខាងអ្នកថែរក្សាបន្ទាប់

ក៖ ចាស!

ខ៖ ដល់ពេលហើយកាលនឹងគេអោយយើងដាក់ពីរ នឹងមីងដាក់ខាងថែរក្សាបន្ទប់នឹងមួយ ហើយនឹងមួយទៀតមីងដាក់ខាងផ្នែកហិរញ្ញវត្ថុមួយ ហើយទៅក៏បានជាប់ខាងហិរញ្ញវត្ថុនឹង ហើយមីងនឹកឃើញថាបើយើងមិនអង់គ្លេសច្បាស់ផងអោយទៅខាងនឹងម៉េចនឹងចេះ? ក៏សុំគេដូរខាងគណនេយ្យ ហើយខាងក្រុមហ៊ុននឹងក៏គេថាអត់ទេ ចាំចូលរៀនសិនបើមិនចេះទេចាំទៅ ស្រាប់តែមួយអាទិត្យហើយមួយអាទិត្យរហូតដល់កន្លះឆ្នាំ មីងដាច់ចិត្តប្រាប់គេថាមីងទៅមិនរួចទេមិនចេះមើលលុយដុល្លារនឹងទេបើវាដូចតែគ្នាចឹងនោះ គេមិនព្រមអោយមីងឈប់គេនៅតែអោយរៀនទៀតមីងក៏ព្យាយាមៗហើយព្យាយាមទៀតយូរទៅក៏ចេះទៅ
ហើយនៅយូរៗទៅយើងចេះនិយាយថ្មីកម៉ងឡើងចង់ភ្លេចខ្មែរចុះគេនៅនឹងគេមិនអោយយើងនិយាយភាសាខ្មែរទេ។

ក៖ ចាស ចុះកាលនឹងមីងចេះប៉ុន្មានភាសាដែរ?

ខ៖ ចេះតែភាសាបារាំងមួយនឹង

ក៖ ហើយនឹងភាសាបារាំងមួយទៀត?

ខ៖ តែបារាំងអីចង់ភ្លេចវិញអស់ហើយ។

ក៖ ចុះសព្វថ្ងៃមីងមានមុខរបរធ្វើអីដែរ?

ខ៖ មីងរាល់ថ្ងៃនៅធ្វើនៅក្នុងរោងចក្រនឹងម៉ង។

ក៖ នៅភ្នំពេញឬនៅតាមខេត្ត?

ខ៖ នៅក្នុងចាក់អង្រែយើងនឹង!

ក៖ ចុះអ្នកមីងធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ?

ខ៖ មីងធ្វើចាប់ពីម៉ោង៧ កន្លះព្រឹកដល់ម៉ោង១១ចេញ ហើយម៉ោង១ចូលម៉ោងប្រាំចេញ មួយថ្ងៃ៨ម៉ោង។

ក៖ ហេតុអីបានជាអ្នកមីងផ្លាស់ប្តូរការងារ?

ខ៖ កាលនឹងមីងធ្វើការកាំបូឌីយ៉ាណាទេ ដល់ពេលហើយកាសែតរស្មីកម្ពុជាជនជាតិជប៉ុននឹងណាស់ គេទៅព្រលានយន្តហោះហើយជាធ្វើការនឹងព្រលានយន្តហោះនឹងគេរើសយកតែពីកាំបូឌីយ៉ាណានឹងទេព្រោះសំបូរអ្នកស្អាតៗ ហើយក្រុមហ៊ុនដែលទៅរើសបុគ្គលិកពីកាំបូឌីយ៉ាណានឹងក្រុមហ៊ុនកាសែត មានសណ្ឋាគារអីគេទៅបញ្ចុះបញ្ចូលអោយយើងទៅធ្វើការអោយគេ ហើយកាលនឹងប្រាក់ខែ១៨ដុល្លារនឹង។

ក៖ ក្នុងមួយខែ?

ខ៖ ចាស បើខាងអ្នកអនាម័យអីនឹងប្រាក់ខែពីររយ ហើយតែខាងផ្នែកមីងទេដែលមានប្រាក់ខែទាបជាងគេដោយសារតែគេថាយើងមានលុយធីបច្រើន។

ក៖ ចាសអ្នកមីងដោយសារតែអ្នកមីងធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍ជីវិតនឹងមកច្រើនហើយចឹងតើអ្នកមីងមានពាក្យពេចន៍អ្វីដើម្បីផ្តាំផ្ញើរក៏ដូចជាអោយក្មេងជំនាន់បានស្តាប់នៅសំលេងរបស់អ្នកមីងចាស់?

ខ៖ មីងគ្រាន់តែចង់ផ្តែផ្តាំទីដល់ក្មេងៗជំនាន់ក្រោយថា ទីមួយសុំអោយជៀសវៀងពីគ្រឿងញៀន ព្រោះគ្រឿងញៀនវាមិនដែលផ្តល់ផលល្អដល់អ្នកប្រើទេក្មួយ។

ក៖ ចាស!

ខ៖ ហើយទីពីអោយក្មួយៗខិតខំរៀនសូត្រព្រោះមានតែចំណេះដឹងទេដែលជាដើមទុកចំរាប់យើងទៅថ្ងៃមុខ ហើយជាធនធានដែលមិនចេះរីងស្ងួត យើងទៅដល់ណាក៏មានការងារធ្វើព្រោះយើងមានសមត្ថភាពធ្វើការអោយគេចឹងហើយក្មួយៗត្រូវតស៊ូជំនះអោយបាន

ដូចមីងណាក្មួយ មីងងើបតាំងាំពីម៉ោង៩ទៀបភ្លឺធាក់កង់ទៅរៀនក្រោយវាំងន៍ ហើយរៀនតែមួយម៉ោងទេ
ឆ្លៀតចេញពីនឹងទៅធ្វើការនៅរោងចក្រទៀតដើម្បីបានបទពិសោធន៍បន្ថែមសំរាប់ទៅធ្វើការ នៅកន្លែងផ្សេង
ចឹងហើយក្មួយៗដែលជាក្មេងសារក្រោយជំនាន់ក្រោយមិមបាច់ធ្វើអោយលើសមីងទេ
អោយបានតែប្រហែលមីងទៅដឹងដែរអនាគតនឹងល្អប្រសើរហើយមិនបាច់ភ័យថាមិនមានការ ងារធ្វើទេ
អោយតែព្យាយាមមីងសព្វថ្ងៃសឹងថាបើមានអ្នកធ្វើការផ្ទះជំនួសមីងទៅរៀនទៀតហើយ
មីងរៀននៅតែចូលនឹង មីងអោយតែខាងរៀនសូត្រនឹងអាចចាប់បានម៉ងមិនដឹងម៉េច។

ក៖ ចាស អ្នកមីងកាលពីមុនអ្នកមីងមានបំណងចង់ធ្វើជាអីដែរ?

ខ៖ អឹម កាលមុនមីងមិនដឹងថាខ្លួនឯងចង់ធ្វើអីទេ បើឪពុកម្ដាយយើងក្រចឹងមានតែឆ្លៀតរៀន ដូចថាពេលព្រឹកយើងដើររើសសំបកកំប៉ុកហើយពេលល្ងាចទៅរៀនក្មួយ សំរាទរៀនណាស់ ហើយក្មេងសារក្រោយដែលជាទំពាំងស្នងឫស្សីនឹង ខិតខំយកចិត្តទុកដាក់រៀនសូត្រ ចៀសអោយឆ្ងាយពីគ្រឿងញៀន ហើយស្ដាប់ដំបូលន្មានឪពុកម្ដាយយើង។

ក៖ ចាស
ចឹងជាចុងក្រោយក្មួយសុំអរគុណអ្នកមីងយ៉ាងជ្រៀលជ្រៅដែលបានចំណាយពេលវេលាដ៏មាន តំលៃអោយក្មួយបានសំភាសន៍ក៏ដូចជាការចែករំលែកនូវបទពិសោធន៍នៃជីវិតរបស់អ្នកមីងផ្ទាល់
សុំជូនពរអោយអ្នកមីងមានសុខភាពល្អនិងមានសុភមង្គលក្នុងគ្រួសារចាសសុំអរគុណអ្នកមីង ។

ខ៖ ចាសក្មួយ អរគុណដូចគ្នា។